ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ : 012 សរ.សហវ

រាជធានីភ្នំពេញ.ថ្ងៃទី 03 ខែ ៣ ឆ្នាំ១៩៩៩

# សារាចរ

## ស្តីពីការប្រមូលចំណូលពីទ្រព្យសម្បត្តិសាធារណៈ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានតួនាទីភារកិច្ចគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងមូល បានកំណត់ទិសដៅ សំរាប់ការគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ នៃរបបសេដ្ឋកិច្ចទីផ្សារ ។

ដើម្បីធានាដល់ការគ្រប់គ្រងថវិកា ខាងផ្នែកចំណូលពីការជួលទ្រព្យសម្បត្តិសាធារណៈដូចជា ភាស៊ីផ្សារ កំពង់ផែ ចំណតរថយន្ត ចំណតទូកកាណូត យៀត្រ៊ី (កំពង់ផែនេសាទ) ទីសត្តឃាតដ្ឋាន ...។ល។ និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានក្នុងវិស័យសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ខេត្ត-ក្រុង និងស្ថាប័ននានាដូចតទៅ ៖

១-ការដាក់ជួលទ្រព្យសម្បត្តិសាធារណៈដូចជា ផ្សារ កំពង់ផែ ចំណតរថយន្ត ចំណតទូកកាណូត យៀត្រ៊ី (កំពង់ផែនេសាទ) ទីសត្តឃាតដ្ឋាន ... ។ល។ និងទ្រព្យសម្បត្តិផ្សេងៗទៀត មានក្នុងវិស័យសាធារណៈ ត្រូវធ្វើការប្រមូលផ្តុំដេញថ្លៃទាំងអស់ នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ដោយរៀបចំលិខិតបទដ្ឋានតាមនីតិវិធីដេញថ្លៃជាសាធារណៈរៀងរាល់អាណត្តិនីមួយៗ ក្រោមការរៀបចំដឹកនាំរបស់អភិបាលខេត្ត-ក្រុង ។

-កំណត់ហេតុនៃការដេញថ្លៃ និងសៀវភៅបន្ទុកភាស៊ី ត្រូវមានការឯកភាពយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-លោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវចាត់មន្ត្រីមានសមត្ថកិច្ចធ្វើការស្រាវជ្រាវបន្ថែមនូវទ្រព្យសម្បត្តិសាធារណៈទាំងឡាយណា ដែលអាចដាក់ជួលនិងត្រូវរៀបចំបែបបទ លិខិតបទដ្ឋាននានាសំរាប់ធ្វើការដេញថ្លៃនូវទ្រព្យសម្បត្តិសាធារណៈទាំងនោះ ។

ចំណូលបានពីការដេញថ្លៃនូវទ្រព្យសម្បត្តិសាធារណៈទាំងអស់(យោងតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨) ត្រូវបង់ចូលខ្ទង់ថវិកាខេត្ត-ក្រុងទាំងអស់ នៅរតនាគារខេត្ត-ក្រុង។

២-ប្រាក់កក់បណ្តោះអាសន្ន ប្រាក់កក់ធានាស្ថាពរ ប្រាក់ថ្លៃឈ្នួល និង ប្រាក់ពិន័យបទល្មើស ត្រូវបង់នៅរតនាគារខេត្ត-ក្រុងសាមីជាប្រាក់រៀល ដោយបំពេញបែបបទនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ។

-ត្រូវផ្ទេរប្រាក់ទាំងនេះចូលថវិកាខេត្ត-ក្រុងជាបន្ទាន់មិនអនុញ្ញាតឱ្យរក្សាទុកក្នុងគណនីប្រាក់បញ្ញើ របស់ធនាគារ ឬស្ថាប័នណាមួយឡើយ ។

-ត្រូវគោរពនិងអនុវត្តដោយម៉ឺងម៉ាត់បំផុត តាមបទបញ្ញត្តិគតិយុត្តិនានា ។ ករណីដែលស្ថាប័នជំនាញ គ្រប់គ្រងលើចំណូលពីការជួលទ្រព្យសម្បត្តិសាធារណៈបណ្ដែតបណ្ដោយពុំមានវិធានការម៉ឺងម៉ាត់ឱ្យ ទាន់ពេលវេលា បណ្ដាលឱ្យបាត់បង់ចំណូលនោះ ប្រធានស្ថាប័នជាអ្នកទទួលខុសត្រូវទាំងស្រុង ។

៣-ក្នុងករណីផ្ទេរសិទ្ធិកែលំអរ សាងសង់ដូចជា ផ្សារ, ចំណតរថយន្ត, ចំណតទូក-កាណូត, កំពង់ផែ, យៀត្រិ(កំពង់ផែនេសាទ), ទីសត្តឃាតដ្ឋាន, . . . ។ល។ រួមទាំងការប្រមូលនិងដឹកជញ្ជូនសំរាម ដើម្បីធ្វើអាជីវកម្ម-សេវាកម្ម ក៏ដូចជាការវិនិយោគទុនឯកជនលើទ្រព្យសម្បត្តិសាធារណៈផ្សេងៗទៀត ត្រូវធ្វើសំណើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤-រាល់ចំណូលភាស៊ីគ្រប់ប្រភេទ ពីទ្រព្យសម្បត្តិសាធារណៈទាំងឡាយ ទោះមាន ឬគ្មានការវិនិយោគថ្មីក្ដី ត្រូវរៀបចំដាក់ឱ្យដេញថ្លៃជាសាធារណៈ ។ ប្រសិនបើមិនអាចដាក់ឱ្យដេញថ្លៃបានទេ ត្រូវស្នើសុំការ យល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-ពេលបញ្ចប់កិច្ចសន្យា ទីតាំង និង ទ្រព្យសម្បត្តិសាធារណៈ ដូចជាអាគារ ផ្ទះល្វែង, និងតូប-រានដែលបានជួលឱ្យអាជីវករលក់ដូរក្នុងនិងក្រៅបរិវេណផ្សារ ត្រូវប្រគល់ជាទ្រព្យសម្បត្តិរដ្ឋវិញទាំងអស់ ។ រីឯថ្លៃឈ្នួលអាគារ ផ្ទះល្វែង.. និងតូប-រាន ត្រូវកំណត់ថ្លៃសាជាថ្មីសំរាប់ជួលក្នុងអាណត្តិថ្មី ហើយ ចំណូលពីការជួលត្រូវបង់ចូលថវិកាខេត្ត-ក្រុង (យោងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ ខេត្ត-ក្រុង) ។

៥-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត-ក្រុង ជាអ្នកតាមដាន និងគ្រប់គ្រងចំណូលនេះ ។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវបូកសរុបជារបាយការណ៍ ឱ្យបានទៀងទាត់ជារៀងរាល់ខែ នៅថ្ងៃទី០៥ ខែបន្ទាប់ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) ។

រាល់ការដេញថ្លៃទ្រព្យសម្បត្តិសាធារណៈ ត្រូវមានតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចូលរួម ។ ក្រោយពីបានទទួលសារាចរនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមថា ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់សាលាខេត្ត-ក្រុងនឹងមានវិធានការអនុវត្តក្នុងការប្រមូលចំណូលពីទ្រព្យសម្បត្តិសាធារណៈ មានប្រសិទ្ធិភាពខ្ពស់បំផុត ជាក់ជាពុំខាន ។

ចំលងជូន

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-គ្រប់សាលាខេត្ត-ក្រុង

-ធនាគារជាតិ

-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង

-ឯកសារ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់